**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ០១៣ សហវ

ថ្ងៃអង្គារ ១០កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដំណាក់កាលទី១ ជំហានទី២

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបង្កើតប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (Non-Tax Revenue Management Information System - NRMIS) ដែលដាក់ឱ្យដំណើរការប្រើប្រាស់ក្នុងដំណាក់កាលទី១ ជំហានទី១ រួចហើយ តាមរយៈលិខិតជូនដំណឹងលេខ០០២ សហវ ចុះថ្ងៃទី២២ ខែ កុម្ភៈ ឆ្នាំ២០១៨។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ NRMIS ដំណាក់កាលទី១ ជំហានទី២ ចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៨ នេះតទៅ។

ដើម្បីឱ្យប្រព័ន្ធនេះដំណើរការបានរលូន ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងនិរន្តរភាព ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជម្រាបជូនដំណឹងដល់ធនាគារជាតិនៃកម្ពុជា, ធនាគារដៃគូ និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ មេត្តាជ្រាបដូចតទៅ÷

ក. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានតម្រូវឱ្យក្រសួង ស្ថាប័នចំនួន០៩ បន្ថែមទៀត ប្រើប្រាស់លេខកូដសម្រាប់បង់ចំណូលមិនមែនសារពើពន្ធ (ចំណូលពីសេវាសាធារណៈ, ចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត)។

ខ. នៅដំណាក់កាលទី១ ជំហានទី២ នេះ ក្រសួង ស្ថាប័ន ដែលត្រូវអនុវត្ត រួមមាន÷ ក្រសួងព្រះបរមរាជវាំង, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្រសួងការពារជាតិ, ក្រសួងព័ត៌មាន, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងបរិស្ថាន, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងយុត្តិធម៌។

គ. បេឡាករនៃធនាគារជាតិនៃកម្ពុជា ធនាគារដៃគូ និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ ត្រូវបញ្ចូលលេខវិក្កយបត្រ ឬលេខកូដចំណូលដែលបានបោះពុម្ពចេញពីប្រព័ន្ធ NRMIS ទៅក្នុងបង្កាន់ដៃបង់ប្រាក់ (កន្លែងបរិយាយ/អត្ថន័យនៃការបង់ចំណូល) ដើម្បីផ្តល់ភាពងាយស្រួលក្នុងការផ្ទៀងផ្ទាត់ប្រភពចំណូលជាមួយក្រសួង ស្ថាប័នទាំង ០៩ នោះ។

ឃ. ក្នុងករណីដែលចំណូលមិនមែនសារពើពន្ធទាំងឡាយណាពុំមានកំណត់លេខកូដទេនោះ ក្រសួង ស្ថាប័នសាមី ពុំអាចបង់ចំណូលទាំងនោះបានឡើយ ហើយត្រូវស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ ឬ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ) ដើម្បីអនុម័តលេខកូដជូន។

ង. អតិថិជន ឬ ក្រសួង ស្ថាប័នសាមី មិនអាចបង់សាច់ប្រាក់ចូលគណនីទោលរតនាគារ TSA តិចជាង ឬ ច្រើនជាងទឹកប្រាក់នៅលើវិក្កយបត្រដែលបានបោះពុម្ពចេញពីប្រព័ន្ធ NRMIS ឡើយ (ចំពោះតែចំណូលពីសេវាសាធារណៈ)។

ការរៀបចំលេខកូដសម្រាប់បង់ចំណូលមិនមែនសារពើពន្ធ (ចំណូលពីសេវាសាធារណៈ ចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត) ត្រូវបានកំណត់ជាទម្រង់ ដូចខាងក្រោម÷

***លេខកូដបង់ចំណូលថ្នាក់ជាតិ÷*** MMM-TT-*៩៩៩៩*


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ: ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax : 855-23-427 798

- MMM : លេខកូដរបស់ក្រសួង ស្ថាប័ន ឬ អង្គភាព (3 ខ្ទង់ខាងមុខ)
- TT : ប្រភេទចំណូលពីសេវាសាធារណៈ ឬ ចំណូលពីទ្រព្យសម្បត្តិរដ្ឋ (2 ខ្ទង់បន្ទាប់)
- ៩៩៩៩ : លេខរៀងចំណូលពីសេវាសាធារណៈ ឬ ចំណូលពីទ្រព្យសម្បត្តិរដ្ឋ (4 ខ្ទង់ចុងក្រោយ)

❖ *កំណត់សំគាល់* (TT) ÷

ក. ផ្នែកកូដចំណូលពីសេវាសាធារណៈ÷ លេខ 01

ខ. ផ្នែកកូដចំណូលពីទ្រព្យសម្បត្តិរដ្ឋ÷ 02 ការជួល, 03 ភាគលាភ, 04 កាតព្វកិច្ចកាស៊ីណូ, 05 សម្បទាន, 06 ផលនេសាទ, 07 អាកាសចរស៊ីវិល (053070001 Credit Loan,053070002 Airport Division Supervisory (ADS Profit Sharing), 08 ផ្សេងៗ, 09 ពិន័យ, 10 កាតព្វកិច្ចឆ្នោត និង 11 ផលពីសម្បទាន។

➢ ឧទាហរណ៍ទី១÷ ចំណូលពីសេវាសាធារណៈ÷

**សេចក្តីពន្យល់÷ ឧទាហរណ៍អំពីការបង់ចំណូលនៅធនាគារ÷** 110010001។

- 110 = ក្រសួងព័ត៌មាន (ឈ្មោះក្រសួង ស្ថាប័ន)
- 01 = ប្រភេទចំណូលពីសេវាសាធារណៈ (ប្រភេទចំណូលសេវា)
- 0001 = លេខរៀងចំណូលពីសេវាសាធារណៈ (លេខរៀងទី ១)

ខ្លឹមសារ÷ ផ្សព្វផ្សាយពាណិជ្ជកម្មតាមប៉ាណូ - រយៈពេល 1 ឆ្នាំ។

➢ ឧទាហរណ៍ទី២÷ ចំណូលពីសេវាសាធារណៈ÷

**សេចក្តីពន្យល់÷ ឧទាហរណ៍អំពីការបង់ចំណូលនៅធនាគារ÷** 190010001។

ខ្លឹមសារ÷ ប្រាក់ពិន័យបទល្មើសធនធានធម្មជាតិ ពិន័យអន្តរការណ៍ (បទល្មើសធនធានធម្មជាតិថ្នាក់ទី1) របស់ក្រសួងបរិស្ថាន។

➢ ឧទាហរណ៍ទី៣÷ចំណូលពីទ្រព្យសម្បត្តិរដ្ឋ÷

**សេចក្តីពន្យល់÷ ឧទាហរណ៍អំពីការបង់ចំណូលនៅធនាគារ÷** 054020001។

ខ្លឹមសារ÷ ចំណូលពីការជួល កោះអូន កោះបង ក្រុងព្រះសីហនុ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

➢ ឧទាហរណ៍ទី៤÷ ចំណូលពីទ្រព្យសម្បត្តិរដ្ឋ÷

**សេចក្តីពន្យល់÷ ឧទាហរណ៍អំពីការបង់ចំណូលនៅធនាគារ÷** 110020001។

ខ្លឹមសារ÷ ចំណូលពីការជួលអគារលេខ ២៦២ មហាវិថីព្រះមុនីវង្ស(សណ្ឋាគារមិត្តភាព)របស់ក្រសួងព័ត៌មាន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមធនាគារជាតិនៃកម្ពុជា, ធនាគារដៃគូ និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ មេត្តាជ្រាប និងផ្តល់កិច្ចសហការអនុវត្តប្រកបដោយប្រសិទ្ធភាព។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន÷**
- ធនាគារជាតិនៃកម្ពុជា
- ធនាគារ កម្ពុជាសាធារណៈភីអិលស៊ី
- ធនាគារ អេស៊ីលីដា ភីអិលស៊ី
- ធនាគារ កាណាឌីយ៉ា ក.អ
- ធនាគារ ឯកទេសវីង (ខេមបូឌា) លីមីធីត
- ធនាគារ វឌ្ឍនៈ
- ធនាគារ អេ អ៊ិន ហ្សេត រ៉ូយ៉ាល់
- ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ
- គ្រឹះស្ថានហិរញ្ញវត្ថុដៃគូ
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ